អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០

# សេចក្តីប្រកាសព័ត៌មាន

## ការតែងតាំងចៅក្រមអង្គបុរេជំនុំជម្រះឡើងវិញ

បន្ទាប់ពីមានការតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក Ban Ki-moon និងការអនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរួចមក ព្រះមហាក្សត្រព្រះបាទនរោត្តម សីហមុនី បានតែងតាំង លោកស្រី Catherine Marchi-Uhel (មកពីប្រទេសបារាំង) ធ្វើជាចៅក្រមអន្តរជាតិថ្មីបម្រើការងារនៅអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

លោកស្រីចៅក្រម Marchi-Uhel ដែលមានតួនាទីជាចៅក្រមបម្រុងអន្តរជាតិនៅអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក រហូតដល់ថ្ងៃតែងតាំងនេះ បំពេញការងារជំនួសឲ្យលោកស្រី ចៅក្រម Kathinka Lahuis (មកពីប្រទេសហូឡង់)។ ពេលនេះ លោកស្រីចៅក្រម Lahuis នឹងបម្រើការងារជាចៅក្រមបម្រុងអន្តរជាតិរបស់អង្គបុរេជំនុំជម្រះវិញ។ លោកចៅក្រម Florence Mumba (មកពីប្រទេសហ្សំប៊ី) ត្រូវបានតែងតាំងធ្វើជាចៅក្រមបម្រុងថ្មីរបស់អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក។

ដោយសារកំណើនការងាររបស់អង្គបុរេជំនុំជម្រះ នាពេលនេះ អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក នឹងបំពេញការងាររបស់ខ្លួនពេញម៉ោង។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:

លោក Lars Olsen
មន្ត្រីផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទដៃ: ៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរស័ព្ទ: ៨៥៥ (0) ២៣ ២១៩ ៨១៤ លេខបន្ត ៦១៦៩
អ៊ីម៉ែល: olsenl@un.org

លោក ឌឹម សុវណ្ណារុំ
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទដៃ: ៨៥៥-១២ ៤៨៨ ០៩៤
ទូរសា: ៨៥៥-២៣ ២១៩ ៨១៤
អ៊ីម៉ែល: dim.sovannarom@eccc.gov.kh

លោកស្រី Yuko Maeda

មន្ត្រីទទួលបន្ទុកផ្នែកកិច្ចការសាធារណៈ

ទូរស័ព្ទដៃៈ ៨៥៥-១២ ៤៨៨ ៣១៩

ទូរស័ព្ទៈ ៨៥៥ (0) ២៣ ២១៩ ៨៤១ លេខបន្ត ៦១៣៩

អ៊ីម៉ែលៈ maeday@un.org